# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ០៨១ MIH / 2016

# ប្រកាស
## ស្តីពី
## ការបង្កើតការិយាល័យច្រកចេញ ចូលតែមួយ
## នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរា ជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសរួម ៧១៧សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ ៖** បង្កើតការិយាល័យច្រកចេញ ចូលតែមួយ នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីសម្របសម្រួល និងបម្រើសេវាសាធារណៈ ជូនប្រជាពលរដ្ឋ ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម ដែលស្ថិតនៅក្រោមច្បាប់ស្តីពីមាត្រាសាស្ត្រ និងច្បាប់នានា ស្ថិតក្រោម សមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ២ ៖** ចាត់តាំងមន្ត្រីការិយាល័យច្រកចេញ ចូលតែមួយនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមាន៖

| | | |
|---|---|---|
| ១-លោក កែ សារី | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | ប្រធាន |
| ២-លោក ម៉ុក់ កិត្យា | អនុប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ | អនុប្រធាន |

**ប្រការ៣ ៖** ត្រូវចាត់តាំងមន្ត្រីប្រចាំការនៅជួរមុខការិយាល័យច្រកចេញ ចូលតែមួយ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមាន៖

| | | |
|---|---|---|
| ១-លោកស្រី ហេង លក្ខិណា | អនុប្រធានការិយាល័យ | ទទួលលិខិតចូល |
| ២-លោក ស្រឿង វ៉ាន់ធឿន | ប្រធានការិយាល័យ | រដ្ឋទេយ្យករចំណូលរង |
| ៣-លោក សេង គឹមស៊ា | ប្រធានការិយាល័យ | រដ្ឋទេយ្យករចំណូលរង |

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥

**ប្រការ៤** ៖ ត្រូវបានចាត់តាំងមន្ត្រីប្រចាំការនៅជួរក្រោយ ការិយាល័យច្រកចេញ ចូល តែមួយនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមាន ៖

| | | |
|---|---|---|
| ១-លោក ស្រស់ រស្មី | ប្រធានការិយាល័យ | សមាជិក |
| ២-លោក ហុង សុខលីដា | អនុប្រធានការិយាល័យ | សមាជិក |
| ៣-លោកស្រី វ៉ោន សំណាង | អនុប្រធានការិយាល័យ | សមាជិក |
| ៤-លោកស្រី សាម សំណាង | អនុប្រធានការិយាល័យ នៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ | សមាជិក |
| ៥-លោក ហេង សាមីឌី | អនុប្រធានការិយាល័យ នៃនាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ | សមាជិក |
| ៦-លោក យឹម សុវិជ្ជា | មន្ត្រីនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម | សមាជិក |

**ប្រការ៥** ៖ ការិយាល័យច្រកចេញ ចូលតែមួយមានភារកិច្ច៖

- ទទួល និងពិនិត្យឯកសារ រួចបញ្ជូនទៅតាមនាយកដ្ឋានជំនាញ ដើម្បីអនុវត្តតាមបែបបទ និងនីតិវិធី
- ពិនិត្យឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ រួចចេញលិខិតអនុញ្ញាតបង់ប្រាក់ជូនអតិថិជន ទៅបង់ប្រាក់នៅបញ្ជរបង់ប្រាក់ដែលស្ថិតនៅក្នុងទីតាំងច្រកចេញ ចូលតែមួយ
- ពិនិត្យ ទទួលសាច់ប្រាក់ រួចចេញបង្កាន់ដៃបង់ប្រាក់ជូនអតិថិជន
- ដំណើរការផ្តល់សេវា ដោយតម្លាភាព និងគណនេយ្យភាពតាមគោលការណ៍ច្រកចេញ ចូលតែមួយ
- ធ្វើរបាយការណ៍បូកសរុបចំណូលសេវាសាធារណៈ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងអគ្គនាយកដ្ឋានកិច្ចការទូទៅ
- បំពេញភារកិច្ចផ្សេងទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួង។

**ប្រការ៦** ៖ ត្រូវបានចាត់តាំងមន្ត្រីប្រចាំការផ្នែកទទួលពាក្យបណ្តឹង និងត្រួតពិនិត្យ នៃការិយាល័យច្រកចេញ ចូលតែមួយ នៃ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិចំនួន០១នាក់។

**ប្រការ៧** ៖ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨** ៖ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល** ៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-អង្គភាពប្រឆាំងអំពើពុករលួយ

"ដើម្បីជូនជ្រាប"

-ដូចប្រការ៨ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ